ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៩២

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩

សាលដីកា

លេខ: ៧១ (I)

ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រមរបាយការណ៍

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

នៅលើបណ្ដឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] វ៉ាន្នី ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ [redacted] David Noel M ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៨ "ក្រVI បស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ:**

១-ឈ្មោះ [redacted] David Noel M (ជាអ្នកប្ដឹងសាទុក្ខ) ភេទប្រុស កើតឆ្នាំ១៩៨៣ ជនជាតិ [redacted] កាន់លិខិតឆ្លងដែនលេខ [redacted] កើតនៅប្រទេស [redacted] មានទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ជានីតិជន នៅលីវ។

Scanned with CamScanner

ឃុំខ្លួនតាមដីកាបង្គាប់លេខ ៣៤១ (វ) ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

-មានមេធាវីការពារលោកស្រី [redacted] កល្យាណ ។

-អ្នកបកប្រែភាសាឈ្មោះ [redacted] ថនសុខេង ។

ខ-ឈ្មោះ [redacted] Eddie J Taller ភេទប្រុស អាយុ៣៧ឆ្នាំ មុខរបរមិនពិតប្រាកដ ជនជាតិ [redacted] កាន់លិខិតឆ្លងដែនលេខ [redacted] កើតនៅប្រទេស [redacted] មានទីលំនៅបច្ចុប្បន្ន [redacted] ជានីតិជន។

**ជាប់ចោទពីបទ ៖** ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្ថិតនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៩ និង៣០នាទី នៅចំណុចអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅរាជធានីភ្នំពេញ មានអំពើ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើងដែលមុនពេលកើតហេតុ កម្លាំងនគរបាលការិយាល័យរដ្ឋបាលសរុប(ក១) នៃមន្ទីរប្រឆាំងគ្រឿងញៀន បានធ្វើការស៊ើបអង្កេតពីករណីខាងលើជាច្រើនថ្ងៃ ពីដំណើររឿងដឹកជញ្ជូនគ្រឿងញៀន ពីទីក្រុងសៅប៉ូឡូញ ប្រទេស [redacted] តាមជើងយន្តហោះ ET507 នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ មកកាន់អាឌីសអាបាបា និងបន្តដំណើរមកទីក្រុងបាងកកប្រទេសថៃ តាមជើងយន្តហោះ ET507 នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ រួចបន្តដំណើរចុងក្រោយមកដល់ប្រទេសកម្ពុជា នៅចំណុច និងកាលបរិច្ឆេទខាងលើ ពេលនោះសមត្ថកិច្ចឃាត់ខ្លួនបានជនត្រូវចោទឈ្មោះ [redacted] David Noel M ភេទប្រុស អាយុ៣៤ឆ្នាំ និងដកហូតបានម្សៅក្រាមចំនួន ០២ កញ្ចប់ ទម្ងន់១០០៣.២៤ក្រាម (ធ្វើតេស្តបឋមប្រភេទកូកាអ៊ីន)

ដែលលាក់បង្កប់ក្នុងវ៉ាលីរបស់ជនត្រូវចោទឈ្មោះ [redacted] David Noel M រួមនឹងវត្ថុតាងមួយចំនួនទៀតបញ្ជូនទៅមន្ទីរប្រឆាំងគ្រឿងញៀនដើម្បីចាត់ការតាមនីតិវិធី។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] David Noel M បានឆ្លើយសារភាពថា ខ្លួនទទួលដឹកជញ្ជូនគ្រឿងញៀនពីប្រទេសប្រេស៊ីលមកប្រទេសកម្ពុជា តាមបញ្ជារបស់ឈ្មោះ [redacted] Eddie J Taller ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិ [redacted] ដោយបានទទួលកម្រៃឈ្នួល ចំនួន ៣០.០០០ ដុល្លារ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៥៤ ក្រ២ "ឃ" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

Scanned with CamScanner

ក-ឈ្មោះ [redacted] David Noel M. ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិ [redacted]

ខ-ឈ្មោះ [redacted] Eddie J Taller ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិ [redacted]

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេលអស់មួយជីវិត និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ៨០ លានរៀល ពីបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] Eddie J Taller ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិប៊ែលហ្សិក ដែលមានអត្តសញ្ញាណដូចខាងលើដើម្បីយកមកអនុវត្តទោស ។

៣-វត្ថុចាប់យក ៖

ក-ស្រោមពណ៌គគីរបិតជិតសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅម៉ត់ពណ៌ស ទម្ងន់ ១០០៣,២៤ ក្រាម (មួយពាន់បីក្បៀសម្ភៃបួនក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] David Noel M. ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង សំបុត្រយន្តហោះ ចំនួន ០១សន្លឹក វ៉ាលី ពណ៌ខ្មៅ ចំនួន ០១ និងទូរស័ព្ទដៃម៉ាក Nokia ចំនួន ០១គ្រឿង និងទូរស័ព្ទដៃចំនួន ០១គ្រឿង ម៉ាក Xiao Mi ពណ៌ទឹកប្រាក់ រ៉ឺបអូស ។

ខ-លិខិតឆ្លងដែនលេខ EN 106323 ចំនួន ០១ និងអត្តសញ្ញាណប័ណ្ណប៊ែលហ្សិក លេខ ៥៩១-៧១៨៧៧១៧-២២ ចំនួន០១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ [redacted] David Noel M. កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] Eddie J Taller និងប្រកាស នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៧៣ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] David Noel M ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល និងបណ្តឹងឧទ្ធរណ៍លេខ ៤៧៦ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] David Noel M ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រIV "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៧៣ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] David Noel M ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៥៤ ក្រ២ “ឃ” ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] David Noel M ប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] David Noel M ។ បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ សារណាការពារ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកស្រី [redacted] កល្យាណ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] David Noel M ដាក់ជូនតុលាការកំពូលរួចហើយ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៩ និង៣០នាទី ជនជាប់ចោទឈ្មោះ [redacted] David Noel M ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង រួមទាំងគ្រឿងញៀន(កូកាអ៊ីន) ០២ កញ្ចប់ ទម្ងន់ ១០០៣.២៤ ក្រាម បង្កប់នៅក្នុងវ៉ាលីរបស់ជនជាប់ចោទ នៅព្រលានយន្តហោះអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

-យល់ឃើញថា អំពើរបស់ជនជាប់ចោទ គឺជាបទ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់បញ្ញត្តិឱ្យផ្តន្ទាទោសមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-យល់ឃើញថា មេធាវីរបស់ជនជាប់ចោទបានលើកឡើង ពីមូលហេតុនៃបណ្តឹងសាទុក្ខថាកូនក្តីខ្លួនសហការជាមួយសមត្ថកិច្ចដឹងកំហុសរបស់ខ្លួន ទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ មានម្តាយចាស់ជរាត្រូវមើលថែរក្សា សំណូមពរសុំឱ្យតុលាការផ្តល់ស្ថានសម្រាលផ្តន្ទាទោស ចន្លោះពី១៥ឆ្នាំ ទៅ៣០ឆ្នាំ វិញ។ ការលើកឡើងមិនអាចទទួលយកបាននោះទេ ដោយហេតុថា បរិមាណគ្រឿងញៀនមានចំនួនច្រើន បើគ្មានការទប់ស្កាត់ទាន់ពេលនោះទេ វាធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គម។

-យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ដែលមានសម្រេចមកនេះ មានភស្តុតាងនិងសំអាងហេតុត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ។

Scanned with CamScanner

## ហេតុដូច្នេះ

## តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច:

តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រIV "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

ស្នូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់។

+ជនជាប់ចោទឈ្មោះ [redacted]David Noel M ឆ្លើយថាខ្ញុំកើតនៅឆ្នាំ១៩៨៣ ស្នាក់នៅចល័តច្រើនកន្លែង ការងារពីមុនខ្ញុំលក់បីហ្គឺរសព្វថ្ងៃខ្ញុំឃុំខ្លួននៅព្រៃស។ ក្នុងរឿងនេះខ្ញុំសុំទទួលសារភាពនេះជាលើកទី១ ដែលខ្ញុំធ្វើខុសសូមខ្ញុំទឹកដល់ម្តាយខ្ញុំសោកស្តាយដែលខ្ញុំដឹកគ្រឿងញៀនពីប្រទេសប្រេស៊ីលព្រោះ មានគេអោយប្រអប់ខ្ញុំមួយបិទជិតគ្មាននរណាមើលឃើញទេ ។

+លោកស្រីមេធាវី [redacted] កល្យាណ ការពារជនជាប់ចោទឈ្មោះ [redacted]David Noel M ធ្វើសេចក្តីសន្និដ្ឋានថានាងខ្ញុំ សុំឯកភាពតាមសារណាការពាររបស់នាងខ្ញុំ មូលហេតុកូនក្តីនាងខ្ញុំប្តឹងសាទុក្ខមកនេះគឺគាត់សុំបន្ធូរបន្ថយទោសដល់គាត់ព្រោះគាត់បានទទួលសារភាពរាល់កំហុសរបស់គាត់យោងតាមមាត្រា៩៣,មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌផ្តន្ទាទោសគាត់អស់មួយជីវិត សុំអោយផ្តន្ទាទោសគាត់តែ១៥ឆ្នាំ ដល់៣០ឆ្នាំ តែប៉ុណ្ណោះបានហើយ ។ ស័ណ្ឋមពរ សុំសំរាលទោសដល់គាត់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដានការពាររបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] វ៉ាន់ឌី ជា អ្នកទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted]David Noel M ក្នុងការប្តឹងសាទុក្ខសាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់



Scanned with CamScanner

តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ ,មាត្រា ៤២០ និងមាត្រា៤២២ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនា ការ មានខ្លឹមសារប្រហាក់ប្រហែលគ្នាទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនដែរថា បណ្តឹងសាទុក្ខ លេខ ១៧៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] រ័ទ្ធី ជាអ្នកទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទ ឈ្មោះ [redacted] David Noel M ក្នុងការប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVI “ប.ស” ចុះថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការនេះ គឺស្របគ្នាទៅនឹងផ្នែកសំអាង ត្រង់ចំណុចទី១ របស់តុលាការកំពូលដែរ ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងនូវអំណះ អំណាងរបស់ខ្លួនថា ជនជាប់ចោទឈ្មោះ [redacted] David Noel M ត្រូវបានកងកម្លាំងមានសមត្ថកិច្ចឃាត់ខ្លួនជាករណី បទល្មើសជាក់ស្តែង រួមទាំងរឹបអូសបាននូវគ្រឿងញៀន ២ កញ្ចប់ មានទម្ងន់សរុប ១.០០៣,២៤ក្រាម ដែលជនជាប់ ចោទបានដាក់បង្កប់ក្នុងវ៉ាលីដាក់ខោអាវរបស់ខ្លួននៅចំណុចព្រលានយន្តហោះអន្តរជាតិពោធិចិនតុង នោះគឺជាបទល្មើស ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ដែលតាមបញ្ញត្តច្បាប់ឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ ស្តីពីការត្រួត ពិនិត្យគ្រឿងញៀន។ ឯសារណារបស់មេធាវីការពារក្តីឱ្យជនជាប់ចោទបានលើកឡើងពីមូលហេតុនៃបណ្តឹងសាទុក្ខថា *“កូនក្តីរបស់ខ្លួនបានសហការជាមួយនឹងសមត្ថកិច្ច បានដឹងពីកំហុសរបស់ខ្លួន កូនក្តីរបស់ខ្លួនទើបតែ ប្រព្រឹត្តជាលើក ទី១ មានបញ្ហាគ្រួសារ មានម្តាយចាស់ជរាត្រូវការអ្នកមើលថែរក្សា និងសំណូមពរសុំឱ្យតុលាការផ្តល់នូវស្ថានសម្រាល ទោស ដោយដាក់ពន្ធនាគារចន្លោះពី ១៥ ឆ្នាំ ដល់ ៣០ ឆ្នាំ”* នោះ មិនអាចទទួលយកបានទេ ដោយហេតុថា បរិមាណ សារធាតុញៀនដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើសដឹកជញ្ជូនមានបរិមាណធាតុសុទ្ធយ៉ាងច្រើន ។ ប្រសិនបើគ្មាន ការបង្ក្រាប ទប់ស្កាត់បានទាន់ពេលវេលាទេនោះ វានឹងអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមជាតិជាមិនខាន។ ហើយបាន អះអាងថា សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះមានសំអាងលើអង្គហេតុ ភស្តុតាង អង្គច្បាប់ ត្រឹម ត្រូវហើយ ដែលគប្បីតុលាការកំពូលសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVI “ប.ស” ចុះថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល នោះគឺជាសេចក្តីសន្និដ្ឋាននិងប្តឹងសុំមានមូលដ្ឋាន សំអាងលើអង្គហេតុ ភស្តុតាង អង្គច្បាប់យ៉ាងត្រឹមត្រូវហើយ តុលាការកំពូលយល់ស្របនឹងអំណះអំណាងនេះ ។

Scanned with CamScanner

៤-យល់ឃើញថា អំណះអំណាងរបស់ជនជាប់ចោទឈ្មោះ [redacted] David Noel M ថា ខ្លួនពិតជាបានស៊ីឈ្នួលនាំយកថ្នាំញៀន ដែលដាក់វេចខ្ចប់រុំផ្លាស្ទិកដាក់ក្នុងវ៉ាលី ដោយជិះតាមយន្តហោះចេញពីប្រទេសប្រេស៊ីលឆ្ពោះ មកកម្ពុជាតាមច្រកទ្វារព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ហើយត្រូវបានកងកម្លាំងមានសមត្ថកិច្ចផែកឆែករក ឃើញនៅក្នុងវ៉ាលីរបស់ខ្លួនពិតប្រាកដមែន។មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ដោយសារតែខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ ខ្លួនមានការសោកស្តាយយ៉ាងខ្លាំង ដែលបានប្រព្រឹត្តនូវ កំហុសដ៏ធំបែបនេះ និងសុំឱ្យតុលាការជួយសម្រាលទោសដល់ខ្លួនផងនោះ គឺជាអំណះអំណាងមិនមានមូលហេតុនៃ បណ្តឹងសាទុក្ខ និងមិនមានស្ថានសម្រាលពិសេសដែលមានបញ្ញត្តក្នុងច្បាប់ដែលជាហេតុនាំឱ្យតុលាការកំពូលអាច យកមកពិចារណាជាស្ថានសម្រាលទោសតាមបទប្បញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌបានឡើយ ដោយមូលហេតុបរិមាណសុទ្ធនៃសារធាតុញៀន ដែលជនជាប់ចោទបានដឹកជញ្ជូននោះជាប្រភេទកូកាអ៊ីនមានទម្ងន់ រហូតដល់ ៨០៦,៧០(ប្រាំបីរយប្រាំមួយក្បៀសចិតសិប) ក្រាមងណោះ។ គ្រាន់តែករណីធម្មតាដែលច្បាប់បានកំណត់ "ថ្នាំញៀនជាប្រភេទ*កូកាអ៊ីន*ដែលមានបរិមាណសុទ្ធចាប់ពី ៨០ ក្រាម ឡើងទៅ នឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ចាប់ពី ២០ ឆ្នាំ ទៅដល់ ៣០ ឆ្នាំ ឬអស់មួយជីវិតតាមបទប្បញ្ញត្តិត្រង់ចំណុចទី៣ កថាខណ្ឌទី៧ មាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១២ ។

៥.យល់ឃើញថា សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទបានអះអាងថា "*ជនជាប់ចោទជា កូនក្តីរបស់ខ្លួនបានទទួលស្គាល់នូវអំពើដែលគាត់បានប្រព្រឹត្ត សារភាពនូវកំហុសថា ខ្លួនពិតជាបានដឹកជញ្ជូនគ្រឿង ញៀនេះពីប្រទេសប្រេស៊ីលមកកម្ពុជា គឺដើម្បីទទួលបានកម្រៃមួយចំនួន ពីព្រោះកូនក្តីរបស់ខ្លួនមានបញ្ហាគ្រួសារ មានម្តាយចាស់ជរាគ្មានអ្នកមើលថែ សំណូមពរក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោស គ្រាប្រណីទោសឱ្យកូនក្តីរបស់ខ្លួនផង និង សំណូមពរសុំឱ្យតុលាការផ្តល់នូវស្ថានសម្រាល ទោស ដោយដាក់ពន្ធនាគារចន្លោះពី ១៥ ឆ្នាំ ដល់ ៣០ ឆ្នាំ" តាម បទប្បញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ*" នោះ គឺជាអំណះអំណាងមិនត្រឹមត្រូវនិងមានមូលដ្ឋានលើ អង្គហេតុ ភស្តុតាង អង្គច្បាប់សមស្របឡើយ។ ដោយមូលហេតុដូចតុលាការកំពូលបានលើកបង្ហាញក្នុងសំអាងហេតុ ទី២ ខាងលើនេះរួចហើយ។ សេចក្តីសន្និដ្ឋាន និងអំណះអំណាងរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទក៏មិនមាន មូលហេតុបណ្តឹងសាទុក្ខ ដូចមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៦.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌ ២៨ ក្រVI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ ។

Scanned with CamScanner

**ហេតុដូច្នេះ**

**សម្រេចសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៧៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] David Noel M ដែលបានប្តឹងតាមរយៈលោកមេធាវី [redacted] វ៉ាន់ធី ជាអ្នកទទួលសិទ្ធិតំណាងក្នុងការប្តឹងសាទុក្ខ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVI "ប.ស" ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២០ និងប្រកាសសាលានៅការជាសាធារណៈ នៅថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner